អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## ប្រទេសអូស្ត្រាលីផ្តល់ជំនួយថវិកាបន្ថែមចំនួន ១,៤ លានដុល្លារអូស្ត្រាលី ដល់ អ.វ.ត.ក

ប្រទេសអូស្ត្រាលីបានផ្តល់ជំនួយថវិកាបន្ថែមចំនួន ១,៤ លានដុល្លារអូស្ត្រាលី (ប្រមាណ ១,៤៦ លានដុល្លារអាមេរិក) ដល់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)។ ជំនួយថវិកាថ្មីនេះដែលត្រូវបានប្រកាសដោយឯកឧត្តម បប់ ខារ រដ្ឋមន្ត្រីការបរទេស និងជាសមាជិកសភាអូស្ត្រាលី ក្នុងអំឡុងដំណើរទស្សនកិច្ចជាផ្លូវការរបស់ឯកឧត្តមនៅរាជធានីភ្នំពេញកាលពីខែកក្កដា ឆ្នាំ២០១២ ត្រូវបានផ្ទេរទៅអង្គការសហប្រជាជាតិរួចហើយ។

ជំនួយថវិកាលើកនេះគឺបន្ថែមទៅលើថវិកាចំនួន ១,៦១ លានដុល្លារអូស្ត្រាលី ដែលប្រទេសអូស្ត្រាលីបានផ្តល់ដល់ភាគីទាំងពីរនៃ អ.វ.ត.ក កាលពីដើមឆ្នាំ២០១២នេះ។ បូករួមទាំងជំនួយលើកនេះផង ប្រទេសអូស្ត្រាលីបានផ្តល់ជំនួយថវិកាដល់ អ.វ.ត.ក សរុបចំនួន ១៩,៧១ លានដុល្លារអូស្ត្រាលី ហើយ។

ឆ្លើយតបនឹងជំនួយដ៏មានតម្លៃនេះ ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក ឃ្នុត រ៉ូសិនហាក អនុប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក បានថ្លែងថា៖ "ក្នុងនាម អ.វ.ត.ក យើងសូមថ្លែងអំណរគុណចំពោះទឹកចិត្តសប្បុរសរបស់រដ្ឋាភិបាលអូស្ត្រាលី ដែលបន្តផ្តល់ការគាំទ្រដល់ដំណើរការរបស់ អ.វ.ត.ក។ ក្នុងកាលៈទេសៈដែល អ.វ.ត.ក កំពុងតែជួបប្រទះការលំបាកផ្នែកថវិកា ជំនួយនេះមានតម្លៃថ្លៃថ្លាជាទីបំផុតដើម្បីធានាថា អ.វ.ត.ក អាចបន្តបេសកកម្មរបស់ខ្លួនដោយពុំមានភាពរអាក់រអួល"។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យ អ.វ.ត.ក
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh